long beach unified school district

**OFFICE OF THE ASSISTANT SUPERINDENT, HIGH SCHOOL**

*Carol Ortega/Ed Samuels/Sashya Tullo – High School Summer School Coordinators*

# កម្មវិធីរៀនរដូវក្តៅសម្រាប់កម្រិតថ្នាក់វិទ្យាល័យ
# ពត៌មានរាយបង្ហាញទូទៅ 2021

## សិទ្ធិចុះឈ្មោះ និង កន្លែងសាលារៀន

កម្មវិធីរៀនរដូវក្តៅសម្រាប់កម្រិតថ្នាក់វិទ្យាល័យ គឺបើកទទួលសិស្សទាំងអស់ ដែលរៀនក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ឡុងប៊ីច និង ត្រូវការរៀនសងឡើងវិញជាពិន្ទុ គ្រេឌិត សម្រាប់ការបញ្ចប់ថ្នាក់ទទួលជាសញ្ញាប័ត្រ, បំពេញស្របតាមការតម្រូវរៀនយកថ្នាក់ a – g, រៀនយកថ្នាក់គណិតសាស្រ្តសម្រាប់ការត្រៀមទុក ឬ រៀនយកពិន្ទុ គ្រេឌិត ពីថ្នាក់ដើមវិញ ។ សិស្ស ដែលទើបបញ្ចប់ថ្នាក់ទី 8 រហូតដល់សិស្ស ដែលទើបបញ្ចប់ថ្នាក់ទី 12 គួរជួបជាមួយអ្នកផ្តល់ឳវាទរបស់គេរៀងៗខ្លួន ដើម្បីយល់ដឹងអំពីសិទ្ធិចុះឈ្មោះរៀនយកថ្នាក់ចាំបាច់ ឬ ថ្នាក់ផ្សេងៗ ដែលផ្តត់ផ្គង់ដោយក្រសួងអប់រំ ឌីស្រ្ទីគ ។ ការចុះឈ្មោះយកថ្នាក់សម្រាប់កម្មវិធីរៀនរដូវក្តៅ គឺបើកទទួលជាចំនួនកំណត់សម្រាប់តែសិស្សរៀននៅតាមវិទ្យាល័យក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ឡុងប៊ីច ប៉ុណ្ណោះ ។ ការចូលរៀនប្រចាំថ្ងៃនៅក្នុងថ្នាក់ គឺចែងតម្រូវឱ្យធ្វើតាមជាកម្រិត 85% សម្រាប់ទទួលពិន្ទុ គ្រេឌិត នៅតាមថ្នាក់មិនមែនជា Apex ។ សិស្សនឹងមិនអាចរៀនជាប់ថ្នាក់បានទេ បើសិនជាគេឈប់ពីថ្នាក់មិនមែនជា Apex លើសជាងចំនួន 10 ម៉ោង (4 ថ្ងៃ) ។ សិស្សទាំងអស់ត្រូវចុះឈ្មោះរៀនជាមួយថ្នាក់ ដើម្បីទទួលជាពិន្ទុ គ្រេឌិត ។

សាលារៀន Browning, Cabrillo, CAMS, Jordan, Lakewood, McBride, Millikan, Poly, Renaissance, Sato និង Wilson នឹងបើកកម្មវិធីទទួលសិស្សទើបរៀនបញ្ចប់ថ្នាក់ទី 8 រហូតដល់សិស្សទើបរៀនបញ្ចប់ថ្នាក់ទី 12 ។ សិស្សកំពុងរៀននៅតាមវិទ្យាល័យសព្វថ្ងៃគួរចុះឈ្មោះយកថ្នាក់សម្រាប់កម្មវិធីរៀនរដូវក្តៅនៅតាមកន្លែងដដែល ដែលពួកគេនឹងត្រឡប់ចូលរៀនវិញនៅក្នុងឆ្នាំសិក្សា ។ សិស្សមកពីសាលារៀន Beach/Reid គួរចុះឈ្មោះយកថ្នាក់នៅតាមវិទ្យាល័យស្ថិតនៅក្បែរផ្ទះ បើសិនជាថ្នាក់ ដែលពួកគេត្រូវការនឹងមានបើកទទួលនៅតាមកន្លែងនោះ ។ បើសិនជាថ្នាក់ត្រូវការគ្មានសម្រាប់បើកទទួលនៅតាមសាលារៀនរបស់អ្នកទេ ចូរអ្នកទាក់ទងទៅកាន់អ្នកផ្តល់ឳវាទរបស់អ្នក ដើម្បីពិគ្រោះអំពីអ្វីផ្សេង ដែលអាចធ្វើបាន ។

ថ្នាក់ទាំងអស់នឹងបើកទទួលសម្រាប់សិស្សចូលរៀនផ្ទាល់នៅក្នុងសាលារៀន ។ យើងមានថ្នាក់តាមចំនួនកំណត់សម្រាប់សិស្សទាំងឡាយណា ដែលស្នើសុំកម្មវិធីរៀនរដូវក្តៅជារបៀប អនឡាញ ។ ការស្នើសុំ គឺនឹងធ្វើការថ្លឹងថ្លែងមើលសម្រាប់សិស្សម្នាក់ៗ ។

**ច្បាប់តម្រូវសម្រាប់ឯកសណ្ឋាន:** LBUSD នឹង**តម្រូវ**ឱ្យសិស្សស្លៀកពាក់ជាឯកសណ្ឋានជាមួយកម្មវិធីរៀនរដូវក្តៅ**នៅតាមសាលា Millikan និង Wilson** ។

**អាហារថ្ងៃត្រង់ដោយមិនបង់ថ្លៃ:** អាហារថ្ងៃត្រង់នឹងចែកផ្តល់ទៅកាន់សិស្សទាំងអស់ ។

### ថ្ងៃខែ និង ម៉ោងសម្រាប់កម្មវិធីរៀនរដូវក្តៅ

| ថ្ងៃខែសម្រាប់កម្មវិធីរៀនរដូវក្តៅ | ម៉ោងសម្រាប់កម្មវិធីរៀនរដូវក្តៅ | |
|---|---|---|
| | **វេនទី 1** | **វេនទី 2** |
| **ថ្ងៃទី28 មិថុនា ទៅ ថ្ងៃទី30 កក្កដា 2021** | **7:50 – 10:15 ព្រឹក** | **10:35 – 1:00 រសៀល** |

**សេចក្តីចំណាំ:** ឆែកមើលនៅតាមសាលារៀនរបស់អ្នកអំពីម៉ោងរៀនច្បាស់លាស់នៅក្នុងថ្នាក់ ដោយមូលហេតុថា សាលារៀនខ្លះប្រើម៉ោងខុសគ្នាបន្តិចសម្រាប់ពេលចេញលេង និង ឬ ទទួលចំណី ។

## មធ្យោបាយចុះឈ្មោះយកថ្នាក់

1. ឆ្លើយបំពេញក្រដាសដាក់ពាក្យ អនឡាញ តាមរយៈ ParentVue: https://parentlbusd.lbschools.net/enrollment ពីថ្ងៃទី7 ខែឧសភា ទៅ ថ្ងៃទី28 ខែឧសភា ។
   a. ក្បួនបង្ហាញរបៀបឆ្លើយបំពេញក្រដាសដាក់ពាក្យសម្រាប់កម្មវិធីរៀនរដូវក្តៅ
2. មាតាបិតានឹងបានទទួលជា អ៊ីម៉ែល បញ្ជាក់អំពីក្រដាសដាក់ពាក្យសម្រាប់កម្មវិធីរៀនរដូវក្តៅ ដែលពួកគាត់បានឆ្លើយបំពេញសម្រាប់សិស្សរបស់ពួកគាត់ ។
3. សិស្សអាចជ្រើសរើសយកថ្នាក់សម្រាប់រដូវក្តៅ ដោយធ្វើតាមជំហានដូចតទៅ ក្បួនបង្ហាញការជ្រើសរើសយកថ្នាក់ ។ បើពុំដូច្នោះទេ អ្នកផ្តល់ឳវាទរបស់អ្នកនឹងជ្រើសរើសយកថ្នាក់ ដែលអ្នកនឹងត្រូវការសម្រាប់បំពេញស្របច្បាប់តម្រូវពីថ្នាក់ a – g ។ សិស្ស ឬ មាតាបិតាអាចបើកមើលបានអំពីថ្នាក់តាមការស្នើសុំ បន្ទាប់ពីអ្នកផ្តល់ឳវាទបានវាយបញ្ចូលដាក់ផុតទៅនៅក្នុង StudentVue ឬ ParentVue ។ សូមចំណាំថា អ្នកផ្តល់ឳវាទទទួលមុខងារច្រើនចំណែកណាស់សម្រាប់ប្រុងប្រៀបបញ្ចប់ឆ្នាំសិក្សា ហើយការវាយបញ្ចូលបង្ហាញឈ្មោះថ្នាក់ គឺប្រហែលជាមិនទាន់បានធ្វើរហ័សនោះទេ ទំរាំតែដល់ពេលចុងបញ្ចប់ ឆមាសលើកទី ពីរ សិន ។ ថ្នាក់ ដែលរាប់ជាផ្លូវការបាន គឺនឹងមានបង្ហាញនៅក្នុង ParentVue និង StudentVue ផ្តើមនៅថ្ងៃទី23 ខែមិថុនា ។
4. **ពេលកំណត់សម្រាប់ឆ្លើយបំពេញក្រដាសដាក់ពាក្យ អនឡាញ សម្រាប់កម្មវិធីរៀនរដូវក្តៅ គឺនៅចំពាក់កណ្តាលយប់នៃថ្ងៃទី28 ខែឧសភា ។**